**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

## សូមគោរពជូន

## ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

***ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !***

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយក្តីរំភើបរីករាយជាទីបំផុត ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងកាយមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែខ្លាំងក្លា និងរីកចម្រើនរុងរឿង។

នាឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពស្រឡាញ់យ៉ាងស្មោះស្ម័គ្រចំពោះគុណូបការៈប្រកបដោយគំរូវីរភាពដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** ដែលកន្លងមកតែងបានខិតខំប្រឹងប្រែងលះបង់អស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងធនធានជាអនេកប្បការក្នុងបុព្វហេតុបម្រើជាតិមាតុភូមិឱ្យទទួលបាននូវសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍលើគ្រប់វិស័យជូនព្រះរាជាណាចក្រកម្ពុជា។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមលើកដៃប្អូងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះព្រំនូវសព្ទសាធុការពរជ័យ ជូន **ឯកឧត្តម** និង **លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២៧៨ email: generalsec@mod.gov.kh